**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សភា រដ្ឋប្បវេណី
សំណុំរឿងរដ្ឋប្បវេណី
លេខ: ២៤៦
ចុះថ្ងៃទី ០៣.៩.៩៩
**សាលដីកា**
លេខ: ២០៣
ចុះថ្ងៃទី ៣០.១១.៩៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះនៅថ្ងៃទី៣០.១១.៩៩ ដោយមានសមាសភាពដូចតទៅ:

១- ឯកឧត្តម ........... ជាប្រធាន
២-លោក ................ ជាចៅក្រម
៣- លោក ............... ជាចៅក្រម
៤-លោក ................ ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**
លោក............................

**តំណាងមហាអយ្យការ**
លោក ..................ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ៣៩៧ ចុះថ្ងៃទី ០៥.៧.៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៤៤ ចុះថ្ងៃទី ០១.០២.៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ភហាហភេទ ប្រុស អាយុ ៤៤ ឆ្នាំ ជាតិខ្មែរ របររកស៊ី លក់អង្ករ ទីលំនៅ ផ្ទះលេខ ៦៥ ក្រុមទី ៥ ភូមិកគោ ឃុំជ្រៃ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។ ឪពុកឈ្មោះ ពួន ណូត ម្តាយឈ្មោះ ហួន នួន ប្រពន្ធឈ្មោះ ឆង ងី ។

នឹងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ ជរ ភេទ ប្រុស អាយុ ៣២ ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ដូរទីលំនៅផ្ទះលេខ ៣៦៤អឺ០ ផ្លូវលេខ ២៩៨ ក្រុមទី២ សង្កាត់អូរឡាំពិក ខ័ណ្ឌចំការមន ។ឪពុកឈ្មោះ សុខ សេង "រ"ម្តាយឈ្មោះ ដួង អូន"រ" ប្រពន្ធឈ្មោះ លឹម អៀន ។

មានមេធាវី លោក ..............

កម្មវត្ថុបណ្តឹង ៖ ប្តឹងទាមទារប្រាក់ថ្លៃអង្ករ ២២៩.៣០០បាត

តាមបណ្តឹងសាទុក្ខលេខ ២១៨ចុះថ្ងៃទី ០៥.៧.៩៩ របស់ឈ្មោះ ភហាហបានប្តឹងមិនសុខចិត្តនិងសេចក្តីសំរេចនៃសាលដីកាលេខ ៣៩៧ ចុះថ្ងៃទី០៥.៧.៩៩ របស់សាលាឧទ្ធរណ៍លើចំណុចនៃសាលដីកាទាំងមូល ។

បានឃើញរឿងរដ្ឋប្បវេណីលេខ ២៤៦ ចុះថ្ងៃទី ០៣.៩.៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៣.៦.៩៨ របស់ដើមចោទឈ្មោះ ភូ ហុកហឺ បញ្ជាក់ថាខ្លួនសុំប្តឹងពីឈ្មោះ ជរ ដែលជំពាក់ប្រាក់ខ្លួនចំនួន ២២៩.៣០០បាត ដោយហេតុថានៅថ្ងៃទី ១៨.៥.៩៨ខ្លួនបានទូរស័ព្ទមកឈ្មោះ ធារី ដើម្បីទារប្រាក់ថ្លៃអង្ករ ប៉ុន្តែឈ្មោះ ធារី បានឆ្លើយថាបានប្រគល់ប្រាក់នោះអោយមកខ្លួនតាមរយះឈ្មោះ ជរ គ្រប់ចំនួនហើយ

។ តាមរយៈ ជរពុំបានប្រគល់ប្រាក់មកអោយខ្លួនតាមរយៈ ឈ្មោះ សុង មុំ ក៏ប៉ុន្តែ សុង មុំ បានឆ្លើយថាខ្លួនមិនទាន់បានទទួលប្រាក់ផ្ទេរទេ ។ ក្រោយមកនៅថ្ងៃទី ២៦.៥.៩៨ ខ្លួនបានទទួលវិក័យប័ត្រឈ្មោះ ធារី ឯប្រាក់មិនបានទទួលទេ ។ រឿងនេះខ្លួនសុំតុលាការជួយដោះស្រាយ និង រកយុត្តិធម៌អោយខ្លួនដោយអនុគ្រោះ

បានឃើញសាលក្រមលេខ ០១ "១" ចុះថ្ងៃទី ១៣.០១.៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ២៣ ខែ ០៦ ឆ្នាំ ១៩៩៨ របស់ដើមចោទឈ្មោះ ភូ ហុកហឹទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-បង្គាប់អោយឈ្មោះ ជរ សងប្រាក់ថ្លៃអង្ករចំនួន ២២៩៣០០បាត "ម្ភៃពីរម៉ឺនប្រាំពាន់បីរយបាត" ប្រាក់ថៃអោយទៅអោយឈ្មោះភហហ

ករណីរឹងទទឹងសងត្រូវដាក់គុកបង្ខំរូបរាងកាយឈ្មោះ ជរ និង រឹបអូសទ្រព្យសម្បត្តិរបស់ ជរ លក់ឡាយឡុងដើម្បីជានាសំណងប្រាក់ជំពាក់តាមច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៣-អោយដើមចោទបង់ប្រាក់ប្រដាប់ក្តីមានពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹង១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រៀល បូករួម ៧.០០០រៀលប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រៀល ដែលដើមចោទបង់ទុកជាស្រេច ។

កាលបើហួសឧទ្ធរណ៍ហើយបង្គាប់អោយចុងចម្លើយសងប្រាក់៧.០០០រៀលទៅអោយដើមចោទវិញ និង អោយបង់ពន្ធសមាមាត្រជាប្រាក់មួយភាគរយលើទឹកប្រាក់ ២២៩.៣០០បាត " ម្ភៃពីរម៉ឺនប្រាំបួនពាន់បីរយបាត" ប្រាក់ថៃ ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ៨០ ភាគរយ និង រង្វាន់ក្រឡាបញ្ជីទូទាំងព្រះរាជាណាចក្រកម្ពុជា ២០ភាគរយ ។

៤-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវឧទ្ធរណ៍រយៈពេល ២ខែចាប់ពីថ្ងៃនេះទៅ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០១ " គ" ចុះថ្ងៃទី ១៣.០១.៩៩ របស់ឈ្មោះ ជរ ប្តឹងមិនសុខចិត្តនិងសេចក្តីសំរេចនៃសាលក្រមលេខ ០១ " គ" ចុះថ្ងៃទី ១៣.០១.៩៩ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំនុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការលេខ ៣៩៧ ចុះថ្ងៃទី ០៥.៧.៩៩ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៣.០១.៩៩ របស់ឈ្មោះ ជរ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ០១ " គ" ចុះថ្ងៃទី ១៣.០១.៩៩របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

៣- ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២៣.៦.៩៨ របស់ឈ្មោះ ភហហ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៤- កាត់យកប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍ឧទ្ធរណ៍ចំនួន ១៣.០០០រៀល គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជី ៤៥០រៀល ចំណាយដីកាកោះ ៥.០០០៛ អាជ្ញាធរតុលាការ ៥.០០០រៀល និងបង្គាប់អោយដើមចោទបង់ពន្ធសមាមាត្រ មួយភាគរយលើប្រាក់ ២២៩.៣០០បាត ។

៥- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តីបើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ២១៨ ចុះថ្ងៃទី ០៥.៧.៩៩ របស់លោក ភូ ហុងហ៊ីបានប្តឹងមិនសុខចិត្តនិងសេចក្តីសំរេចនៃសាលដីកាលេខ៣៩៧ចុះថ្ងៃទី ០៥.៧.៩៩ របស់សាលាឧទ្ធរណ៍លើចំនុចនៃសាលដីកាទាំងមូល។

បានឃើញសារណាចុះថ្ងៃទី ០៦.៩.៩៩ របស់លោក ភូ ហុងហ៊ី ។

បានឃើញសារណាតប ចុះថ្ងៃទី ១៧.៩.៩៩ របស់លោក ជរ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា ៖ សាលដីការដ្ឋប្បវេណីលេខ ៣៩៧ ចុះថ្ងៃទី ០៥.៧.៩៩ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះពុំបានធ្វើការអង្កេតលើកស្តុតាងអោយបានច្បាស់លាស់ឡើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាសំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ភូ ហុកហ៊ី នៅពេលជំនំជំរះថា ៖ បានជាខ្លួនប្តឹងសាទុក្ខពីសាលដីការបស់សាលាឧទ្ធរណ៍ ពីព្រោះដោយសារសាលដីកាសាលាឧទ្ធរណ៍ផ្អែកទៅលើសាក្សីចុងចម្លើយគ្មានភស្តុតាង ។ ខ្លួនលក់អង្ករអោយឈ្មោះ ធារី នៅភ្នំពេញ ហើយទទួលប្រាក់នៅខេត្តបាត់ដំបង ។ ខ្លួនបានយកវិក័យប័ត្រជូនគេវិញ ហើយយកលុយមកវិញព្រោះខ្លួនបើកលុយមិនបាន ដោយរកកន្លែងមិនឃើញ ។ ខ្លួនសុំបដិសេធចោលនូវរឿងដែលថាខ្លួនទូរស័ព្ទ ។ ខ្លួនធ្លាប់ទទួលលុយផ្ញើតាម ជរ និង សុង មុំ នេះមិនមែនលើកទី ១ ទេគឺច្រើនលើកហើយ ខ្លួនមិនដែលអោយកំរៃគេទេក្នុងការផ្ញើលុយនេះព្រោះថាគេបានរកស៊ី ។ ក្រុមហ៊ុន ជរ និង សុង មុំ សាខាជាមួយគ្នា ហើយគូភាគីខ្លួនផ្ញើលុយតាម ជរ ។ គាលខ្លួនបើកលុយពី សុង មុំ ពីមុនពុំមក គឺគេហែកវិក័យប័ត្រអោយ ។ ការដែលសាក្សីថាខ្លួនបើកលុយរួចហើយនោះគឺជាការឆ្លើយយករួចខ្លួនព្រោះខ្លួនមិនទាន់បានបើកលុយនេះទេ ។ ធារី ផ្ញើលុយតាម ជរ ទៅ សុង មុំ តែខ្លួនបើកមិនទាន់បាន ។ កាលខ្លួនទៅសួរ សុង មុំ មិនទាន់មានវិក័យប័ត្រទេ តែខ្លួនដឹងថាម៉ូយខ្លួនផ្ញើលុយទៅហើយតាម ជរ ។ ធារី ទូរស័ព្ទទៅខ្លួនថាបង់ប្រាក់ហើយពូ ជរ បានទទួលលុយនោះហើយ ។ ខ្លួនមិនបានមកភ្នំពេញទេ គឺ វិក័យប័ត្រគេផ្ញើតាមឡានទៅបាត់ដំបងអោយខ្លួន សាក្សីឆ្លើយសុទ្ធតែគ្មានការពិត ។

បានស្តាប់ចម្លើរបស់ឈ្មោះ ជរ នៅពេលជំនុំជំរះថា ៖ រឿងលុយនេះសាក្សីបានមកប្រាប់ខ្លួនថា ភហហ ទទួលបាន ១០ម៉ឺនបាតហើយ លុយនេះខ្លួនបង្វែទៅ សុង មុំ ថ្ងៃទី ១៧.៥.៩៨ ។ ក្រុមហ៊ុនខ្លួន និង សុង មុំ មិនមែនជាក្រុមហ៊ុនជាមួយគ្នាទេ គ្រាន់តែជាសាខា ។ លុយបើកដាក់ភ្លាមយកភ្លាម ខ្លួនបានទទួឡកំរៃជើងសារ តែបើទទួលនៅបាត់ដំបង ខ្លួនមិនបានទទួលកំរៃជើងសារទេ ។ ថ្ងៃទី ១៨ ភហហ មិនបានប្រាប់មកខ្លួនទេ ចំណែកវិក័យប័ត្រខ្លួនប្រគល់អោយសុធារី ហើយ ។ ការរកស៊ីនៅតាមផ្សារសេរី គេមិនមានដាក់សក្ខិក្កិកៈដូចធនាគារទេ គេរកស៊ីនិយាយមាត់គ្នាតែម្តង ។

លោក មេធាវី ............. បានធ្វើសេចក្ដីសន្និដ្ឋានការពារអោយចុងបណ្ដឹងសាទុក្ខ និង ជាចុងចម្លើយនៅពេលសវនាការថា ៖ នៅថ្ងៃទី ១៤.៥.៩៨ ភហហ ផ្ញើលិខិតមួយបញ្ជាក់ទៅធារី ដើម្បីផ្ញើលុយអោយខ្លួន ។ នៅថ្ងៃទី ១៦.៥.៩៨ ធារី យកប្រាក់ ២២៥.៣០០បាត មកអោយ ជរ ផ្ញើទៅ សុង មុំ ។ ថ្ងៃទី ១៧.៥.៩៨ ភហហ បើកលុយពីសុង មុំ ។ ការរកស៊ីគឺតាមទម្លាប់គេកំណត់ ៣ថ្ងៃ បើមិនបើកលុយទេបាត់ដំបងបង្វែប្រាក់មកភ្នំពេញ វិញ ។ សាក្សីឈ្មោះសុខ ស្រីមុំ និង អាន សាទាន ឆ្លើយថា ភហហ បានខ្ចីទូរស័ព្ទរបស់ខ្លួនទូរស័ព្ទមក ធារី ថាបានទទួលលុយ ១០ម៉ឺនបាតហើយ សល់ប៉ុន្មានទុកស៊ីការ ។ ភូ ហុកហ៊ី បើកលុយមិនដែលលើស៣ថ្ងៃទេ សុំតុលាការមើលវិភ័យប័ត្រ ។

សំណូមពរ ៖ សូមលោក ក្រុមប្រឹក្សាជំនុំជំរះ មេត្តាដំកល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីស្ដាបចម្លើយ ដោះសាររបស់គូភាគីនិង សេចក្ដីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថាបណ្ដឹសាទុក្ខលេខ ២១៨ ចុះថ្ងៃទី ០៥.៧.៩៩ របស់លោក ភហហ ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើកយករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី ។
- យល់ឃើញថាលើកឡើងក្នុងសារណាចុះថ្ងៃទី ០៦.៩.៩៩ របស់លោក ភហហ ដែលថា លោកទៅបើកប្រាក់នៅថ្ងៃទី ១៨.៥.៩៨ ពីឈ្មោះ យូ រ៉ាត់ ក្រុមហ៊ុន សុង មុំ ប៉ុន្តែលោក យូ រ៉ាត់ ប្រាប់ថាប្រាក់នោះពុំទាន់ធ្លាក់មកដល់ពីភ្នំពេញទេ ដូច្នេះលោក ជរ ត្រូវទទួលខុសត្រូវលើការសងប្រាក់ដល់លោកនោះ ជាការពុំត្រឹមត្រូវឡើង ពីព្រោះថានៅថ្ងៃទី ១៨.៥.៩៨ ដែលលោកទៅបើកប្រាក់ពុំបាន លោកត្រូវប្រាប់ដំណឹងមកលោក ជរ ជាបន្ទាន់ដើម្បីដោះស្រាយ ប៉ុន្តែផ្ទុយទៅវិញលោកទុកទាស់តែលោក យូ រ៉ាត់ រត់បាត់ទើបលោកប្រាប់ថាលោកបើកលុយពុំទាន់បាន ហើយមានសាក្សីបញ្ជាក់ថាលោក ភហហបានបើកប្រាក់ ១០០.០០០បាត រួចហើយ នៅសល់ប្រាក់ ១២៩.៣០០បាតទៀត លោកទុកយកការប្រាក់ ។ ម្យ៉ាងទៀតអតិថិជនដទៃទៀត ដែលត្រូវផ្ញើលុយតាមរយះលោក ជរ នៅថ្ងៃ១៦.៥.៩៨ ដែរនោះបានបើករួចអស់ហើយ ។ ដូច្នេះលោក ជរ ត្រូវបានរួចខ្លួនពីកាតព្វកិច្ចនៃបំណុលនេះ ។
- យល់ឃើញថាសាលដីការដ្ឋប្បវេណីលេខ ៣៩៧ ចុះថ្ងៃទី ០៥.៧.៩៩ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្ដីមកនេះ មានលក្ខណះត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

  ហេតុដូច្នេះ

  វិនិច្ឆ័យសេចក្ដីចំពោះមុខគូក្ដី

១- ទទួលបណ្តឹងសាទុក្ខលេខ ២១៨ចុះថ្ងៃទី ០៥ខែ កក្កដាឆ្នាំ ១៩៩៩របស់លោក ភូ ហុកហ៊ី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនិងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ៣៩៧ ចុះថ្ងៃទី ០៥ខែ កក្កដាឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោក ភហហ បានបង់រួចហើយ គឺ៖

- ពន្ធចុះបញ្ជីក្តីនិង ពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់

បង្គាប់អោយលោក ភហហ បង់ពន្ធសមាមាត្រតាមការកំណត់របស់សាលាឧទ្ធរណ៍ ។

៤- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ។